ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី២ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

**១. សេចក្តីផ្តើម៖**

នៅព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំសិក្ខាសាលាក្រុមប្រឹក្សាបច្ចេកទេសលើកទី២ ឆ្នាំ២០២២ តាមរយៈវីដេអូខនហ្វើរេន(Zoom) ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានសមាជិក សមាជិកា ថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការដៃគូរដែលពាក់ព័ន្ធចូលរួមចំនួន៣៥ រូប ។

**២. គោលបំណងនៃកិច្ចប្រជុំ៖**

កិច្ចប្រជុំផ្តោតសំខាន់លើការពិភាក្សាលើយុទ្ធសាស្រ្តទី១ វឌ្ឍនភាពនៃការអនុវត្តគម្រោងPrEPក្នុងការការពារនៃការឆ្លងមេរោគអេដស៍ ។

**៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ដែលបានអញ្ជើញចូលរួមតាមរយៈវីដេអូខនហ្វើរេន ក្នុងបរិបទប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ និងការចូលរួមទាំងអស់គ្នា។ **ឯកឧត្តម** ក៏បានបញ្ជាក់ពីរបៀបវារៈមួយចំនួនរួមមាន ៖

- ការអនុវត្ត និងវឌ្ឍនភាពនៃការអនុវត្តគម្រោង PrEP ក្នុងការការពារ នៃការឆ្លងមេរោគអេដស៍ ។
- ការរៀបចំ និងកែសម្រួលសមាសភាពក្រុមការងារតាមយុទ្ធសាស្រ្ត
- ការពិភាក្សារួមនិង សំណួរ - ចម្លើយ

ឯកឧត្តមអគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក៏បានលើកបញ្ជាក់ជូនអង្គពិធីថាដោយមានការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គឺ ស្នើសុំឱ្យមានការរៀបចំបែងចែកក្រុមការងារតាមយុទ្ធសាស្រ្តនីមួយៗដោយមានសមាសភាពក្នុងក្រុម ហើយរាល់ការធ្វើបទបង្ហាញគឺត្រូវធ្វើឡើងតាមយុទ្ធសាស្រ្តនីមួយៗផងដែរ ហើយសម្រាប់ឆ្នាំ២០២២នេះកិច្ចប្រជុំនឹងផ្តោតសំខាន់ទៅលើយុទ្ធសាស្រ្តទី១ ដែលទាកទងនឹងការការពារថែទាំ និងព្យាបាល ។ហេតុនេះទើបមានបទបង្ហាញថ្ងៃនេះស្តីពីវឌ្ឍនភាព និងការអនុវត្តPrEP ហើយខាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគនឹងធ្វើបទបង្ហាញជូន ក្នុងពេលនេះ ។ ក្រោយបទបង្ហាញនឹងមានការពិភាក្សារួមដើម្បីផ្តល់នូវធាតុចូលបន្ថែមទៀតហើយនិងធ្វើរបាយការណ៍ជូនកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ ២០២២ នេះ ។

ជាបន្ទាប់ **លោក វេជ្ជបណ្ឌិត ង៉ូវ បូរា** ប្រធានបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានធ្វើបទបង្ហាញស្តីពី PrEP ដែលមាន Agenda ចំនួន៣ ៖

**ក.** Phase implementation of PrEP instead of Pilots

**ខ.** Progress Update as of January 2022

បទបង្ហាញមាន ដូចជា ៖

**ក.** ដោយកម្មវិធី PrEP នេះជាកម្មវិធីថ្មី និងមានការណែនាំពីWHO នៅតំបន់អាស៊ីឱ្យធ្វើការរៀបចំ និងអនុវត្តការងារនេះបានឯកភាពដោយថ្នាក់ដឹកនាំក្រសួងសុខាភិបាលចាប់ផ្តើមពីខែឧសភា ឆ្នាំ២០១៩ គឺចំបរិបទកូវីដ-១៩ តែទោះយ៉ាងណាក៏បានអនុវត្តលើក្រុមគោលដៅបានមួយចំនួនដោយជ្រើសរើសយក Clinic ឈូកសសម្រាប់ការងារនេះ ។

- ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២៖ ចាប់ផ្តើមដំណើរការការផ្សព្វផ្សាយគោលនយោបាយដែលរៀបចំដោយ NCHADS ដោយមានការគាំទ្រពីក្រសួងសុខាភិបាល។

- ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩៖ បានជ្រើសរើស Clinic អង្គការមួយចំនួន និងរៀបចំដាក់ដំណើរការក្នុងខេត្តសៀមរាប ។

- ខែវិច្ឆិកា ឆ្នាំ២០២០៖ បានពង្រីកការគ្របដណ្តប់ទៅ៩ទីតាំងក្នុងរាជធានីភ្នំពេញ និងបណ្តាខេត្តដូចជាបាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ។

- ខែមិនា ឆ្នាំ២០២១៖ បានរៀបចំនៅ Clinic របស់NCHADS ផ្ទាល់ និងរៀបចំទៅជា Friendly service ដើម្បីទទួលអ្នកជំងឺមកទទួលសេវា ។

- ខែសីហា ឆ្នាំ២០២១៖ បានរៀបចំ SOP របស់ PrEP

- ចុងឆ្នាំ២០២១៖បាន Develop PrEP real database ដែលអាចឱ្យ ធ្វើការ Scale up អ្នកជំងឺបានមកទល់ពេលនេះ

- អ្នកមកទទួលសេវាអាច ធ្វើ Self- Testing ហើយបើចង់បានសេវា PrEP ត្រូវពិនិត្យមើលថាតើគាត់ត្រូវនឹងគោលការណ៍ដែរទេ។

- ចំពោះអ្នកមានគោលការណ៍ផ្តល់ជូននូវសេវានេះត្រូវគោរពតាមគោលការណ៍ណែនាំមក Clinic នៅ ខែ ទី ១ ,៣ ,៦ ,៩ និង១២ ដើម្បីតាមដានពីប្រសិទ្ធភាពនៃការប្រើប្រាស់ឱសថ។

- ការ ប្រើប្រាស់ឱសថPrEP មាន២ របៀប គឺប្រើប្រាស់រាល់ថ្ងៃ និងតាម ព្រឹត្តិការណ៍។

**ខ.** វឌ្ឍនភាពនៃការប្រើប្រាស់ឱសថមកដល់ខែមករា ឆ្នាំ ២០២២ ៖

- មាន អតិថិជនកំពុងប្រើប្រាស់ ចំនួន២,៩៧៨ នាក់

- អ្នកមកទទួលថ្មី២៧១ នាក់ក្នុងនោះ៧០ % ជាMSM ហើយ ១៧ % ជា TG និង ១២ % ជាក្រុមប្រជាជនទូទៅ។

-នៅមណ្ឌលសុខភាពទួលគោក និងឈូកសមានការប្រើប្រាស់ចំនួនច្រើនជាងគេបន្ទាប់មក គឺខេត្តបាត់ដំបង Clinic RHAC និងNCHADS Clinic ។

**បញ្ហាប្រឈមមួយចំនួន ៖**

អ្នកជំងឺមកទទួលសេវាត្រូវការសោហ៊ុយមួយចំនួន ហើយមកទល់ពេលនេះដែរយើងបាន និងកំពុងរកមធ្យោបាយ ដើម្បីដោះស្រាយ។

- អ្នកដែលមកទទួលPrEP ក៏មានអ្នកបោះបង់ច្រើនដែរហើយយើងកំពុងតែរៀបចំ Monitor ថាតើត្រូវរៀបចំយ៉ាងដូចម្តេច? ដោយមានកិច្ចប្រជុំប្រចាំត្រីមាស និងពិនិត្យមើលសកម្មភាពការងារលម្អិតតាមរយៈក្រុមការងារ OW នៅតាមបណ្តាផ្នែកពាក់ព័ន្ធ ។
- ការយល់ដឹង PrEP ក្នុងចំណោម KP នៅមានកម្រិតនៅឡើយដែលទាមទារការបណ្តុះបណ្តាលដើម្បីផ្តល់ចំណេះដឹងបន្ថែម ។

## ៤.ការពិភាក្សា និងសំណួរ - ចម្លើយ៖

- លោកវេជ្ជបណ្ឌិត ឡុង ឡារី ប្រធានកម្មវិធីអេដស៍រាជធានីភ្នំពេញ ៖

ការអនុវត្ត និងដំណើរការ PrEP នៅរាជធានីគឺប្រព្រឹត្តទៅដោយរលូន និងមានការកើនឡើងគួរឱ្យចាប់អារម្មណ៍ជាពិសេសនៅមណ្ឌលសុខភាពទួលគោក ស្រុកប្រតិបត្តិចតុមុខដែលធ្វើបានល្អ និងមានអ្នកមកទទួលយកសេវាច្រើនជាងគេហើយមន្ទីរសុខាភិបាលរាជធានីនឹងខិតខំប្រឹងប្រែងពង្រឹង និងពង្រីកសេវានៅទីតាំងផ្សេងៗទៀត។

- តំណាងមកពីក្រសួងការពារជាតិ ៖

ក្រសួងការពារជាតិកន្លងមក ទាក់ទងនឹងយន្តការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍គឺបានអនុវត្តតាមគោលការណ៍ណែនាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏ដូចជាមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ

អេដស៍សើស្បែក និងកាមរោគ ដែលរួមមានការប្រើប្រាស់កម្មវិធីស្រោមអនាម័យហើយថ្មីៗនេះក៏បានដំណើរការ និងអនុវត្តកម្មវិធី PrEP ហើយយើងសង្កេតឃើញថាដោយមានអន្តរាគមន៍ពីដំណើរការនេះធ្វើឱ្យមានការថយចុះនូវអត្រាឆ្លងជាបន្តបន្ទាប់នៅតាម អង្គភាពនានានៅទូទាំងប្រទេស ។

- តំណាងមកពីអង្គការ KHANNA ៖

លោកមានការចាប់អារម្មណ៍ និងរីករាយចំពោះការគិតគូរពង្រីកវិសាលភាពភាពគ្របដណ្តប់ទៅកាន់ ខេត្តភាគខាងត្បូង ដែលជាខេត្តទទួលខុសត្រូវដោយអង្គការ KHANNA ព្រោះថាPrEP ជាកម្មវិធីមួយដែលបាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ចូលរួមក្នុងការទប់ស្កាត់ការឆ្លងថ្មី ជាពិសេសក្នុងចំណោមKPដែលមកដល់បច្ចុប្បន្ននេះត្រូវបានគេដឹងថាមានអត្រាឆ្លងខ្លាំងជាងគេ។ ហេតុនេះក្នុងបរិបកូវីដ-១៩ អន្តរាគមន៍របស់ PrEP គឺបានដើរតួនាទីយ៉ាងសំខាន់បំផុតដើម្បីកាត់ផ្តាច់ការប្រព្រឹត្តដែលមានកម្រិតប្រឈមខ្ពស់ ក្រោមការគាំទ្រពីថ្នាក់ជាតិដែលក្នុងនោះមានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ ហើយអង្គការKHANNA នឹងប្តេជ្ញារួមចំណែកក្នុងការចូលរួមធ្វើយ៉ាងណាសម្រេចបាននូវគោលដៅ៩៥ ទី១ ក្នុងឆ្នាំ ២០២៥ ទៅតាមផែនការយុទ្ធសាស្រ្តរបស់ ថ្នាក់ជាតិ ។

- លោកវេជ្ជបណ្ឌិត អ៊ុក វិជ្ជា ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ៖

ដោយសារតែPrEP ជាប្រភេទ ARV ហើយគោលការណ៍លេបរបស់ថ្នាំនេះមិនមែនជាប់លាប់រៀងរហូតដូច ARV ឡើយ គឺប្រើផ្តោតសំខាន់ទៅលើក្រុមដែលមានកម្រិតប្រឈមខ្ពស់ដែលត្រូវលេបរាល់ថ្ងៃ ។ ដើម្បីទទួលបានប្រសិទ្ធភាពគឺត្រូវលេប៧ថ្ងៃមុនពេលមានដៃគូរួមភេទ បន្ទាប់គឺត្រូវលេបរាល់ថ្ងៃក្នុងកំឡុងពេលមានដៃគូរួមភេទមិនទៀងទាត់។ ក្នុងករណីលែងមានដៃគូរួមភេទ គឺគាត់អាចបន្តតែ១សប្តាហ៍ទៀតប៉ុណ្ណោះបន្ទាប់ពីការរួមភេទចុងក្រោយ ។

ទោះជាយ៉ាងណាក៏ដោយ ស្រោមអនាម័យនៅតែដើរតួនាទីសំខាន់ពេលកំពុងប្រើកម្មវិធី PrEP នេះដើម្បីបង្ការជំងឺកាមរោគ និងការមានផ្ទៃពោះផងដែរ។ អ្នកជំងឺមួយចំនួនដែលមានមុខងារតម្រងនោមខ្សោយគឺមិនអនុញ្ញាតឱ្យប្រើប្រាស់ឡើយ ។

- តំណាងមកពី MHSS ៖

ការទទួលសេវា PrEP នៅបាត់ដំបង និងបន្ទាយមានជ័យ គឺធ្វើឡើងនៅតាមមន្ទីរពេទ្យបង្អែកហើយមានការចំណាយពេលវេលាច្រើនក្នុងការបំពេញបែបបទឯកសារ និងការចំណាយថវិកាធ្វើដំណើរមួយចំនួនដែលជាមូល

ហេតុចម្បងមួយបណ្តាលឱ្យក្រុមប្រឈមមុខខ្ពស់មួយចំនួនមិនព្រមមកទទួលយកសេវា និងធ្វើឱ្យការបោះបង់មានអត្រាធ្លាក់ចុះរហូតដល់៤៥ ភាគរយ។ ហេតុនេះហើយទើបគិតគូពីការរៀបចំដំណើរការ Community PrEP ដើម្បីកាត់បន្ថយពេលវេលាក្នុងការរង់ចាំ និងចៀសផុតពីការចម្លងជំងឺកូវីដ-១៩ ផងដែរ ។

- លោក វេជ្ជបណ្ឌិត ស៊ូ សានិត មកពីមន្ទីរសុខាភិបាលខេត្តបាត់ដំបង ៖

ការប្រើប្រាស់សេវា PrEP នៅមន្ទីរពេទ្យបង្អែក គឺមិនអាចគេចផុតពីការចុះបញ្ជីក្នុងប្រព័ន្ធ PMRS បានទេហេតុនេះចាំបាច់ត្រូវចចារជាមួយមន្ទីរពេទ្យ។ ទាក់ទងនឹងពេលវេលាមកទទួលយកសេវាគួរតែមានការយោគយល់ និងគោរពតាមម៉ោងបម្រើការងាររបស់មន្ត្រីរាជការ។ លោកក៏បានគាំទ្រចំពោះគំនិតផ្តួចផ្តើមរបស់ Community PrEP ដែលអាចផ្តល់ឱ្យអ្នកមកទទួលសេវានូវភាពងាយស្រួល និងឆាប់រហ័សជាងមុន ។

ចុងបញ្ចប់ **ឯកឧត្តម អគ្គលេខាធិការ** បានសំដែងអំណរគុណចំពោះសមាជិក សមាជិកា ដែលកំពុងមានវត្តមានក្នុងកិច្ចប្រជុំដែលបានបង្ហាញចំណាប់អារម្មណ៍ក្នុងបទបង្ហាញដោយមានការចូលរួមសាកសួរ និងការផ្តល់ជាចម្លើយរួមជាមួយនឹងការពិភាក្សាផ្តល់យោបល់យ៉ាងផុលផុស និងបានកំណត់យកសិក្ខាសាលាលើកទី៣ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៩ព្រឹក។

ថ្ងៃពុធ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃពុធទី៩ ខែមីនា ឆ្នាំ២០២២

**អ្នកធ្វើរបាយការណ៍**

ពេជ្រ សុវីដែត

បានពិនិត្យត្រឹមត្រូវ
**ប្រធាននាយកដ្ឋាន**
**ទាក់ទង និងចលនាប្រភពធនធាន**

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់
**អគ្គលេខាធិការ**

**ឈឹម យិនដារ៉េត**